**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ..២៧៣៨០....អពដ

ថ្ងៃ៧៤៨១១១៦ ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០២២

# សេចក្តីណែនាំ
## ស្តីពី
## វិធីគណនាប្រាក់អាកររបស់សហគ្រាសផលិតផលិតផលជាប់អាករពិសេសក្នុងស្រុក

អនុលោមតាមប្រកាសលេខ ០១២សហវ.ប្រក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលការកំណត់មូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុក និងសេចក្តីជូនដំណឹងលេខ ៣៨១២ អពដ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានពន្ធដារ ស្តីពីការអនុវត្តប្រកាសលេខ ៧២៣ សហវ.ប្រក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ ស្តីពីវិធាននៃការប្រើប្រាស់វិក្កយបត្រ និងក្នុងគោលបំណងធានាឱ្យសហគ្រាសផលិតផលិតផលជាប់អាករពិសេសក្នុងស្រុក គណនាប្រាក់អាករលើការផ្គត់ផ្គង់ផលិតផលក្នុងស្រុកបានត្រឹមត្រូវ និងមានសង្គតិភាព អគ្គនាយកដ្ឋានពន្ធដារ សូមណែនាំដូចខាងក្រោម÷

### ក. ករណីប្រើប្រាស់វិក្កយបត្រអាករ (Tax Invoice)

ក្នុងករណីចេញវិក្កយបត្រអាករ ជូនបុគ្គលជាប់អាករក្នុងស្រុក សហគ្រាសត្រូវគណនាប្រាក់អាករពិសេសមុនគេ បន្ទាប់មក អាករសម្រាប់បំភ្លឺសាធារណៈ(បើមាន) និងចុងក្រោយគឺអាករលើតម្លៃបន្ថែម។ ការគណនាប្រាក់អាករនីមួយៗ ត្រូវធ្វើឡើងតាមលំដាប់លំដោយដូចខាងក្រោម÷

១. អាករពិសេស = ៩០% x(គុណ) តម្លៃកត់ត្រាក្នុងវិក្កយបត្រ(តម្លៃផ្គត់ផ្គង់មិនរួមអាករគ្រប់ប្រភេទ) x (គុណ) អត្រាអាករពិសេស

២. អាករសម្រាប់បំភ្លឺសាធារណៈ = [តម្លៃកត់ត្រាក្នុងវិក្កយបត្រ(តម្លៃផ្គត់ផ្គង់មិនរួមអាករគ្រប់ប្រភេទ) +(បូក) ប្រាក់អាករពិសេស] x(គុណ) អត្រាអាករសម្រាប់បំភ្លឺសាធារណៈ

៣. អាករលើតម្លៃបន្ថែម = [តម្លៃកត់ត្រាក្នុងវិក្កយបត្រ(តម្លៃផ្គត់ផ្គង់មិនរួមអាករគ្រប់ប្រភេទ) +(បូក) ប្រាក់អាករពិសេស+(បូក)ប្រាក់អាករសម្រាប់បំភ្លឺសាធារណៈ]x(គុណ) អត្រាអាករលើតម្លៃបន្ថែម។

**ឧទាហរណ៍ទី១÷** រោងចក្រផលិតស្រាបៀរក្នុងស្រុកមួយ បានផ្គត់ផ្គង់ផលិតផលស្រាបៀរឱ្យបុគ្គលជាប់អាករក្នុងស្រុក ក្នុងតម្លៃសរុបចំនួន ១ ០០០ ០០០រៀល (មិនរួមអាករគ្រប់ប្រភេទ)។ ដូចនេះ ប្រាក់អាករត្រូវបានគណនាដូចខាងក្រោម÷

| | | | |
|---|---|---|---|
| A. តម្លៃមិនរួមអាករគ្រប់ប្រភេទ | = 1,000,000 | | |
| B. អាករពិសេស | = 90% x 1,000,000 x 30% | = | 270,000 |
| C. អាករសម្រាប់បំភ្លឺសាធារណៈ | = (1,000,000 + 270,000) x 3% | = | 38,100 |
| D. អាករលើតម្លៃបន្ថែម | = (1,000,000+270,000+38,100)x10% | = | 130,810 |

**ឧទាហរណ៍ទី២÷** រោងចក្រផលិតផលិតបារីក្នុងស្រុកមួយ បានផ្គត់ផ្គង់បារីឱ្យបុគ្គលជាប់អាករក្នុងស្រុក ក្នុងតម្លៃសរុបចំនួន ១ ០០០ ០០០រៀល (មិនរួមអាករគ្រប់ប្រភេទ)។ ដូចនេះ ប្រាក់អាករត្រូវបានគណនាដូចខាងក្រោម÷

| | | | | |
|---|---|---|---|---|
| A. តម្លៃមិនរួមអាករគ្រប់ប្រភេទ | = | 1,000,000 | | |
| B. អាករពិសេស | = | 90% x 1,000,000 x 20% | = | 180,000 |
| C. អាករសម្រាប់បំភ្លឺសាធារណៈ | = | (1,000,000 +180,000) x 3% | = | 35,400 |
| D. អាករលើតម្លៃបន្ថែម | = | (1,000,000+180,000+35,400) x 10% | = | 121,540 |

**ឧទាហរណ៍ទី៣÷** រោងចក្រផលិតភេសជ្ជៈគ្មានជាតិសុរាក្នុងស្រុកមួយ បានផ្គត់ផ្គង់ផលិតផលឱ្យបុគ្គលជាប់អាករក្នុងស្រុក ក្នុងតម្លៃសរុបចំនួន ១ ០០០ ០០០រៀល (មិនរួមអាករគ្រប់ប្រភេទ)។ ដូចនេះ ប្រាក់អាករត្រូវបានគណនាដូចខាងក្រោម÷

| | | | | |
|---|---|---|---|---|
| A. តម្លៃមិនរួមអាករគ្រប់ប្រភេទ | = | 1,000,000 | | |
| B. អាករពិសេស | = | 90% x 1,000,000 x 10% | = | 90,000 |
| C. អាករលើតម្លៃបន្ថែម | = | (1,000,000 + 90,000) x 10% | = | 109,000 |

**ខ. ករណីប្រើប្រាស់វិក្កយបត្រធម្មតា** (Commercial Invoice)

ក្នុងករណីចេញវិក្កយបត្រធម្មតាជូនអតិថិជន ដែលមានន័យថាប្រាក់អាករគ្រប់ប្រភេទត្រូវបានបញ្ចូលទៅក្នុងតម្លៃលក់រួចរាល់ នោះការគណនាប្រាក់អាករត្រូវធ្វើបញ្ច្រាសពីវិធីគណនាខាងលើ ដោយសហគ្រាសត្រូវចាប់ផ្តើមគណនា អាករលើតម្លៃបន្ថែមមុនគេ បន្ទាប់មក អាករសម្រាប់បំភ្លឺសាធារណៈ(បើមាន) និងចុងក្រោយគឺអាករពិសេស។ ការគណនាប្រាក់អាករនីមួយៗ ត្រូវធ្វើឡើងតាមលំដាប់លំដោយដូចខាងក្រោម÷

**១. អាករលើតម្លៃបន្ថែម (អតប)**

មូលដ្ឋានគិតអាករលើតម្លៃបន្ថែម = តម្លៃលក់(តម្លៃរួមអាករគ្រប់ប្រភេទ) ÷ (១ + អត្រាអតប)

អាករលើតម្លៃបន្ថែម (អតប) = មូលដ្ឋានគិតអាករលើតម្លៃបន្ថែម x អត្រា អតប

**២. អាករសម្រាប់បំភ្លឺសាធារណៈ**

មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ = មូលដ្ឋានគិតអាករលើតម្លៃបន្ថែម÷(១+អត្រាអាករសម្រាប់បំភ្លឺសាធារណៈ)

អាករសម្រាប់បំភ្លឺសាធារណៈ = មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ x អត្រាអាករសម្រាប់បំភ្លឺសាធារណៈ (ក្នុងករណីផលិតផលជាប់អាករសម្រាប់បំភ្លឺសាធារណៈ)

**៣. អាករពិសេស**

មូលដ្ឋានគិតអាករពិសេស = 90% x {មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ÷ [១+(៩០% x អត្រាអាករពិសេស)]}

អាករពិសេស = មូលដ្ឋានគិតអាករពិសេស x អត្រាអាករពិសេស ។

**ឧទាហរណ៍ទី៤÷** រោងចក្រផលិតស្រាក្នុងស្រុកមួយ បានផ្គត់ផ្គង់ផលិតផលស្រាឱ្យអតិថិជន ក្នុងតម្លៃសរុបចំនួន ២ ២៣៤ ៨៤៣រៀល (រួមទាំងអាករគ្រប់ប្រភេទ)។ ដូចនេះ ប្រាក់អាករត្រូវបានគណនាដូចខាងក្រោម÷

| | | | | |
|---|---|---|---|---|
| A. តម្លៃរួមទាំងអាករគ្រប់ប្រភេទ | = | 2,234,843 | | |
| B. មូលដ្ឋានគិតអាករលើតម្លៃបន្ថែម | = | 2,234,843 ÷ (1+10%) | = | 2,031,675 |
| C. អាករលើតម្លៃបន្ថែម | = | 2,031,675 x 10% | = | 203,168 |

D. មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ = 2,031,675 ÷ (1+3%) = 1,972,500

E. អាករសម្រាប់បំភ្លឺសាធារណៈ = 1,972,500 x 3% = 59,175

F. មូលដ្ឋានគិតអាករពិសេស = 90%x{1,972,500 ÷ [1+(35%x 90%)]} = 1,350,000

G. អាករពិសេស = 1,350,000 x 35% = 472,500

**ឧទាហរណ៍ទី៥÷** រោងចក្រផលិតស៊ីហ្គាក្នុងស្រុកមួយ បានផ្គត់ផ្គង់ស៊ីហ្គាឱ្យអតិថិជនក្នុងស្រុកក្នុងតម្លៃសរុបចំនួន ១ ៣៨៧ ៩២៥រៀល (រួមទាំងអាករគ្រប់ប្រភេទ)។ ដូចនេះ ប្រាក់អាករត្រូវបានគណនាដូចខាងក្រោម÷

A. តម្លៃរួមទាំងអាករគ្រប់ប្រភេទ = 1,387,925

B. មូលដ្ឋានគិតអាករលើតម្លៃបន្ថែម = 1,387,925 ÷ (1+10%) = 1,261,750

C. អាករលើតម្លៃបន្ថែម = 1,261,750 x 10% = 126,175

D. មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ = 1,261,750 ÷ (1+3%) = 1,225,000

E. អាករសម្រាប់បំភ្លឺសាធារណៈ = 1,225,000 x 3% = 36,750

F. មូលដ្ឋានគិតអាករពិសេស = 90%x {1,225,000 ÷ [1+(25%x 90%)]} = 900,000

G. អាករពិសេស = 900,000 x 25% = 225,000

**ឧទាហរណ៍ទី៦÷** រោងចក្រផលិតភេសជ្ជៈគ្មានជាតិសុរាក្នុងស្រុកមួយ បានផ្គត់ផ្គង់ភេសជ្ជៈឱ្យអតិថិជនក្នុងស្រុកក្នុងតម្លៃសរុបចំនួន ១ ១៩៩ ០០០រៀល (រួមអាករគ្រប់ប្រភេទ)។ ដូចនេះ ប្រាក់អាករត្រូវបានគណនាដូចខាងក្រោម÷

A. តម្លៃរួមទាំងអាករគ្រប់ប្រភេទ = 1,199,000

B. មូលដ្ឋានគិតអាករលើតម្លៃបន្ថែម = 1,199,000 ÷ (1+10%) = 1,090,000

C. អាករលើតម្លៃបន្ថែម = 1,090,000 x 10% = 109,000

D. មូលដ្ឋានគិតអាករពិសេស = 90% x {1,090,000 ÷ [1+(10%x 90%)]}= 900,000

E. អាករពិសេស = 900,000 x 10% = 90,000

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមជឿជាក់យ៉ាងមុតមាំថា លោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬម្ចាស់សហគ្រាសផលិតផលិតផលជាប់អាករពិសេសក្នុងស្រុកទាំងអស់នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ប្រកបដោយការទទួលខុសត្រូវ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**